**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៩១ សហវ

*ភ្នំពេញ ថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០០៤*

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*********

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ផ្អែកលើភាពចាំបាច់នៃការងារកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សម្រេច

***

**ប្រការ ១:** បង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហៅកាត់«គកហ» ដែលរួមមានសមាសភាពដូចខាងក្រោម ÷

### I. *ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន*

| | | |
|---|---|---|
| ១- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | អគ្គលេខាធិការ កសហវ | ប្រធាន |
| ២- ឯកឧត្តម **ហាង់ ជួន ណារ៉ុន** | អគ្គលេខាធិការរង កសហវ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ជូ គឹមឡេង** | អគ្គលេខាធិការរង កសហវ | អនុប្រធាន |
| ៤- ឯកឧត្តម **ឆន្ទី ទិស្សេត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៥- ឯកឧត្តម **ជូ ទិព្វចិត្ត** | អគ្គលេខាធិការរង កសហវ | សមាជិក |

### II. *ថ្នាក់ដឹកនាំនាយកដ្ឋាន*

| | | |
|---|---|---|
| ៦- ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៧- ឯកឧត្តម **ទិន យន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធាន រតនាគារជាតិ | សមាជិក |
| ៨- លោក **នួច ឡេង** | ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ៩- លោក **ហុង ថាវ** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១០- លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ | សមាជិក |
| ១១- លោក **គាំង លាងខំណា** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១២- លោក **នាយ នុង** | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៣- លោក **ជាវ ឌុងណារា** | ប្រធាននាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច | សមាជិក |
| ១៤- លោក **លឹម ម៉ិនហៃ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ១៥- លោក **ម៉ម និច** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៦- លោក **ហ៊ាន សាហ៊ីប** | នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៧- លោក **មោក សុធារិន** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៨- លោក **ឃិនន៍ ត័យឈង់** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |

**ប្រការ ២:** គណកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានមុខងារ និង ភារកិច្ចដូចតទៅ ÷

- ធ្វើជាលេខាធិការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំនូវចក្ខុវិស័យ កម្មវិធី និង ផែនការសកម្មភាពនានា សំដៅកែលំអ និង ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របទៅតាមតម្រូវការនៃការ-អភិវឌ្ឍន៍ប្រទេស និង ស្របតាមស្តង់ដារនៃការអនុវត្តន៍នៅក្នុងតំបន់ និងជាអន្តរជាតិ ។
- ដឹកនាំ និង តាមដានការអនុវត្តន៍ចក្ខុវិស័យ កម្មវិធី និង ផែនការសកម្មភាព សំរាប់កែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព លំដាប់លំដោយត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់នៅក្នុងកិច្ចដំណើរការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង រវាងកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ។
- ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការសំរបសំរួលកិច្ចការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងក្រសួង និង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ។
- ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកៀងគរជំនួយ និង ក្នុងការសំរបសំរួលការអនុវត្តន៍កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងដៃគូអ្នកផ្តល់ជំនួយនានា ។

**ប្រការ ៣:** «គកហ» ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង តាមការអញ្ជើញរបស់ប្រធាន ឬ អាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ ៤:** ប្រធាន «គកហ» អាចអញ្ជើញប្រធាននាយកដ្ឋាន មន្ត្រីជំនាញ និង ទីប្រឹក្សាបច្ចេកទេសនានា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមិនមែនជាសមាជិកនៃ «គកហ» ឱ្យចូលរួមប្រជុំទៅតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ ៥:** ក្នុងករណីអវត្តមាន សមាជិកនៃ «គកហ» ដែលជាប្រធាននាយកដ្ឋាន អាចស្នើសុំការ-អនុញ្ញាតពីប្រធាន ដើម្បីចាត់តាំងអនុប្រធាននាយកដ្ឋានមួយរូប ឱ្យចូលរួមប្រជុំជំនួស ។ សមាជិក «គកហ» អាចស្នើសុំការអនុញ្ញាតពីប្រធាន ឱ្យមន្ត្រីជំនាញដែលមានការពាក់

ព័ន្ធផ្ទាល់ទៅនឹងការងារកែទម្រង់នៅក្នុងអង្គភាពរបស់ខ្លួន ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ ។

**ប្រការ ៦:** «គកមហ» ប្រើប្រាស់អង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលេខាធិការដ្ឋានរបស់ខ្លួន ។

**ប្រការ ៧:** «គកមហ» ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន ។

**ប្រការ ៨:** ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ចំលងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃ កសហវ
- គ្រប់នាយកដ្ឋានក្រោមឱវាទ កសហវ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ ឯកសារ